# ស្គាល់ប្រភេទសំណួរដែលមានប្រសិទ្ធភាព

នៅខាងក្រោមនេះគឺជាឧទាហរណ៍នៃសំណួរដែលគ្រូបង្រៀនអាចប្រើនៅពេលបង្រៀនមេរៀនមួយនៅក្នុងដានីយ៉ែល ១-៣។ សំណួរនីមួយៗនឹងជួយដឹកនាំអ្នករៀនឲ្យទទួលបានលទ្ធផលដែលចង់បានទាក់ទងនឹងលំនាំនៃការរៀនសូត្រ ។ សូមអានសំណួរនីមួយៗ ហើយសម្រេចថាជាគុនៃលំនាំការរៀនសូត្រមួយណា ដែលអាចអនុវត្ត ។ នៅក្នុងចន្លោះជិតសំណួរនីមួយៗ ចូរសរសេរស្លាកមួយដូចខាងក្រោម ៖

- **យ.ប.ម** សម្រាប់ ការយល់បរិបទ និងមាតិកា
- **ស.គ.គ** សម្រាប់ ការស្គាល់គោលលទ្ធិ និងគោលការណ៍ទាំងឡាយ
- **យ.គ.គ** សម្រាប់ ការយល់គោលលទ្ធិ និងគោលការណ៍ទាំងឡាយ
- **ទ.ព.ស**សម្រាប់ការទទួលអារម្មណ៍ដឹងពីសេចក្ដីពិត និង សារៈសំខាន់នៃគោលលទ្ធិ និង គោលការណ៍ទាំងឡាយ
- **អ.គ.គ** សម្រាប់ ការអនុវត្តគោលលទ្ធិ និងគោលការណ៍ទាំងឡាយ

________១. គិតអំពីបទពិសោធន៍មួយដែលការអនុវត្តសេចក្ដីជំនឿដូចជាដានីយ៉ែល និងដៃគូរបស់លោក បានប្រទានពរដល់ជីវិតរបស់អ្នក ឬជីវិតអ្នកដទៃ ។ តើជាលទ្ធផលមានពរជ័យអ្វីខ្លះបានកើតឡើង ?

________២. តើឧទាហរណ៍មួយចំនួនអ្វីខ្លះ អំពីស្ថានភាពដែលយុវវ័យសព្វថ្ងៃអាចត្រូវអនុវត្តសេចក្ដីជំនឿដូចជាដានីយ៉ែល និងដៃគូរបស់លោក ?

________៣. ស្របតាមដានីយ៉ែល ៣:២៥តើព្រះអម្ចាស់គង់នៅទីណា នៅពេល សាដ្រាក់ មែសាក់ និង អ័បេឌ-នេកោ ស្ថិតនៅក្នុងគ្រោះថ្នាក់នោះ ?

________៤. តើគោលការណ៍អ្វីខ្លះ ដែលយើងអាចប្រាប់មកពីវគ្គគម្ពីរនេះ ?

________៥. ចូរពិចារណាអំពីគោលការណ៍ដែលយើងបានរកឃើញ តើមានភាពខុសគ្នាអ្វីខ្លះដែលវាមាននៅក្នុងជីវិតរបស់អ្នក បើអ្នកសក្ដិសមចំពោះវត្តមានរបស់ព្រះអម្ចាស់នៅក្នុងគ្រានៃគ្រោះថ្នាក់ដ៏ធំបំផុតរបស់អ្នកនោះ ?

________៦. តើគោលការណ៍អ្វីខ្លះត្រូវបានបង្ហាញដោយដានីយ៉ែល និងដៃគូរបស់លោក ដែលបានបដិសេធពុំទទួលទានអាហាររបស់ស្ដេច ( សូមមើលដានីយ៉ែល ១) ?

________៧. តើយ៉ាងម៉េចបានជា « មនុស្សខ្លាំងពូកែបំផុត » ដែលស្ថិតនៅក្នុងកងទ័ពរបស់ស្ដេច នេប៊ូក្នេសា ត្រូវបានសម្លាប់ (ដានីយ៉ែល ៣:២០; សូមមើលផងដែរ ខ ២២) ខណៈដែលសាដ្រាក់ មែសាក់ និង អ័បេឌ-នេកោ « ចេញពីកណ្ដាលភ្លើងមក » (ខ ២៦)?

________៨. ដូចជាសាដ្រាក់ មែសាក់ និង អ័បេឌ-នេកោ ហេតុអ្វីយើងបដិសេធមិនទទួលទាននូវវត្ថុមួយចំនួនដែលពិភពលោកប្រកាសថាវាល្អយ៉ាងដូច្នេះ ?

________៩. តើឈ្មោះភាសាហេព្រើររបស់សាដ្រាក់ មែសាក់ និង អ័បេឌ-នេកោ ជាអ្វី ? ( សូមមើល ដានីយ៉ែល ១: ៧) ។

________១០. ហេតុអ្វីអ្នកគិតថាព្រះពុំតែងតែការពារពួកសុចរិតពីអន្តរាយ ឬគ្រោះថ្នាក់ជានិច្ចកាលដូច្នេះ ?

________១១. តើត្រង់ចំណុចណាខ្លះនៅក្នុងជីវិតរបស់អ្នក ដែលអ្នកអាចអនុវត្តនូវអ្វីដែលអ្នកបានរៀនមកពីដានីយ៉ែល និងដៃគូរបស់លោក ?



© ២០១៦ ដោយ Intellectual Reserve, Inc. រក្សាសិទ្ធិគ្រប់យ៉ាង ។